**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៦៨

ចុះថ្ងៃទី ២៥ខែ វិច្ឆិកាឆ្នាំ១៩៩៩

សាលដីកា

លេខ ០៥

ចុះថ្ងៃទី ២៤ខែ មីនា ឆ្នាំ២០០០

**នាមនាមប្រជារាស្ត្រខ្មែរ**

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២២ខែ មីនា ឆ្នាំ ២០០០

ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ស៊ិន ឌឹម ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ពេជ តារី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ លេខ ៧២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១៦៨ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍លើដីកាលើកលែងចោទប្រកាន់ទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌ លេខ ៦៨ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

១- ជនជាប់ចោទឈ្មោះ ប៉ាក ផល្លន់ " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបរជាងទង កើតនិង ទីលំនៅសព្វថ្ងៃភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។ ឪពុកឈ្មោះ ប៉ាក ផន ( រ ) ម្តាយឈ្មោះ ប៊ុន អឿន ( រ ) នៅលីវ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

ពីបទ : បោកបញ្ឆោត បង្ខាំងមនុស្សខុសច្បាប់ និង រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំង កក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និង ភូមិព្រែកពៅ ឃុំព្រែកពៅ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ៣១ខែឧសភា ឆ្នាំ ១៩៩៨ ។ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥ , ៣៣ និង ៦៩ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

មានមេធាវី លោក ស្រី សារី

២- ជនជាប់ចោទឈ្មោះ ប៊ុន ហុក " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣២ឆ្នាំ

ជាតិខ្មែរ មុខរបរ គរុសិស្ស ខេត្តកណ្តាល កើត និង ទីលំនៅសព្វថ្ងៃ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ ប៊ុន បូ ( រ ) ម្តាយឈ្មោះ ប៊ុន គី ( រ ) ប្រពន្ធឈ្មោះ ខឹម ប៉ាក់ មានកូន ០១នាក់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

ពីបទ : ផ្សំគំនិត បោកបញ្ឆោត បង្ខាំងមនុស្សខុសច្បាប់ និង រំលោភសេពសន្ថវៈ ប្រព្រឹត្ត នៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និង ភូមិព្រែកញៀ ឃុំព្រែកញៀ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ៣១-៥-៩៨ តាមមាត្រា ៣៥, ៣៣ និង ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មានមេធាវី លោក ស្រី សារី

៣- ជនជាប់ចោទឈ្មោះ ប៊ុន គី " ជាចុងបណ្តឹងទុក្ខ " ភេទស្រី អាយុ ៥៨ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើត និង ទីលំនៅសព្វថ្ងៃ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ ឌិន ប៊ុន " ស " ម្តាយឈ្មោះ ប៉ាល់ គុន ( ស ) ប្តីឈ្មោះ ប៊ូ បូ មានកូន ០១ នាក់ ។ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

ពីបទ : ផ្សំគំនិត បោកបញ្ឆោត បង្ខាំងមនុស្សខុសច្បាប់ និង រំលោភសេពសន្ថវៈ ប្រព្រឹត្ត នៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និង ភូមិព្រែកញៀ ឃុំព្រែកញៀ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី ៣១-៥-៩៨ តាមមាត្រា ៣៥ , ៣៣ និង ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

មានមេធាវីលោក ស្រី សារី

៤- ជនជាប់ចោទឈ្មោះ ប៊ុន អឿន " ជាចុងបណ្តឹងសាទុក្ខ " ភេទស្រី អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ កើត និង ទីលំនៅសព្វថ្ងៃ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឌិន ប៊ុន ( ស ) ម្តាយឈ្មោះ ពៅម សឿ ( ស ) ប្តីឈ្មោះ ប៉ាត ផន មានកូន ០៨នាក់ ។ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

ពីបទ : ផ្សំគំនិត បោកបញ្ឆោត បង្ខាំងមនុស្សខុសច្បាប់ និង រំលោភសេពសន្ថវៈ ប្រព្រឹត្ត នៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល និង ភូមិព្រែកញៀ ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃ ទី ៣១-៥-៩៨ តាមមាត្រា ៣៥, ៣៣ និង ៦៩ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

មានមេធាវី លោក ស្រី សារី

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហួត សុខុន " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ " ជាប្តីរបស់ជនរងគ្រោះឈ្មោះ មុយ លីធាន " មានទីលំនៅ ភូមិព្រែកញៀ ឃុំព្រែកញៀ ស្រុកអង្គស្នួល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ទី ហួត " រ " ម្តាយឈ្មោះ ឃឹម អ៊ុត " រ " ប្រពន្ធឈ្មោះ មុយ លីនាវ មានកូន ០២នាក់ ។

មេធាវីគ្មាន .

- តាមបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ១៩៩៩ របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមកំណត់ហេតុសួរយកចម្លើយ ជនរងគ្រោះ ឈ្មោះ មុយ លីចាន់ ឆ្លើយនៅអយ្យការ និង ចៅក្រមចៅក្រមស៊ើបអង្កេតថា នៅថ្ងៃទី ២៧-៥-១៩៩៨ វេលាម៉ោង ៧ព្រឹក ខ្លួនកំពុងរៀបចំមាសដាក់ក្នុងទូរលក់ដូរ ក៏ឃើញឈ្មោះ ប៊ុន ហុក ជិះម៉ូតូមកតែម្នាក់ឯងប្រាប់ខ្លួនថា ចៃ អាលន់ វាឱ្យខ្ញុំមកឌុបថែងទៅជួបវា នៅបេនរថយន្តស៊ុរិយា ។ ខ្លួន ឮដូច្នេះ ដោយធ្លាប់ថា ដឹងទិញឧបករណ៍ធ្វើមាសឱ្យឈ្មោះ ប៉ាក ផល្លន់ និងមិនទឹកស្មានពីគំនិតគេ ខ្លួនក៏សារមាសពីក្នុងទូរទុកវិញ រួចរៀបចំខ្លួន មានមាស ប្រាក់ ហើយជិះម៉ូតូទៅជាមួយឈ្មោះ ប៊ុន ហុក ដោយយកកូនប្រុសម្នាក់អាយុ ០៥ឆ្នាំ ទៅជាមួយផង ។ ហើយខ្លួនក៏បានផ្តាំឈ្មោះទ្រីន ស្វាយ ត្រូវជាបងប្អូនជីដូនមួយខាងប្តី ឱ្យគាត់ជួយមើលផ្ទះខ្លួនផង ព្រោះប្តីខ្លួនមិននៅផ្ទះ។ ឈ្មោះប៊ុន ហុក បានឌុបខ្លួនដល់បេនឡាស៊ុរិយា ជួបនឹងឈ្មោះប៉ាក ផល្លន់ រួចឈ្មោះប៊ុន ហុក ក៏ជិះម៉ូតូចេញបាត់មួយសន្ទុះ ក៏ឃើញត្រឡប់មកវិញ តែមិនឃើញម៉ូតូទេ។ ក្នុងពេលជាបន្ទាន់នោះដែរ ឈ្មោះ ប៉ាក ផល្លន់ និង ប៊ុន ហុក ក៏បានរុញខ្លួន និង លើកកូនខ្លួនចូលក្នុងឡាន តែម្តង ដោយស្រែកហៅឱ្យគេជួយ ក៏ស្រែកមិនទាន់ដែរ ។ ចំពោះឡាន ទោះជាឡានតាក់ស៊ីពណ៌សធុនតូច ក្នុងឡាននោះ ឈ្មោះ ប៉ាក ផល្លន់ និង ប៊ុនហុក ជិះអមសងខាង កូនខ្លួន អង្គុយលើភ្លៅខ្លួន និង អ្នកបើកបរម្នាក់ ក្រៅពីនេះគ្មានអ្នកណាជិះទៀតទេ ក្រោយពេលចេញដំណើរភ្លាម ឈ្មោះ ប៉ាក ផល្លន់ បានចាក់ប្រេងខ្យល់ និងដៃវា រួចយកមកជូតច្រមុះខ្លួន ក្រោយពេលទទួលក្លិនប្រេងខ្យល់មក ហាក់ដូចភ្លេចភ្លាំងស្មារតី ចេះតែងងុយដេក និង ដឹងខ្លួនម្តង ។ លុះចុះពីឡាន អ្នកទាំងពីរបាននាំខ្លួនដើរទៅផ្ទះមួយ ដែលខ្លួនមិនបានដឹងថា នៅទីនោះភូមិ ឃុំអ្វី កន្លែងណាទេ ព្រោះផ្ទះនោះ នៅដាច់ៗពីគ្នា ហើយព្រៃ និង ភ្នំ នៅព័ទ្ធជុំវិញ ។ នៅពេលមកដល់ផ្ទះនោះ អ្នកទាំងពីរបានជួបជាមួយម្ចាស់ផ្ទះ រួចមនុស្សស្រីម្នាក់ ហៅខ្លួនចូលទៅក្នុងផ្ទះ និង រៀបចំកន្លែងមួយឱ្យខ្លួនស្នាក់នៅជាមួយកូន រួចអ្នកទាំងពីរ បាននិយាយជំរាបខ្លួនថា មិនឱ្យចេញទៅណាទេ ។

- បានឃើញ សេចក្តីសំរេច របស់តំណាងអយ្យការ អម តុលាការខេត្តកណ្តាល ដែលបានសំរេច : ចោទប្រកាន់លើឈ្មោះ ប៉ាក ផល្លន់ អាយុ២៦ឆ្នាំ ពីបទបោកបញ្ឆោតបង្ខាំងមនុស្សដោយខុសច្បាប់ និង រំលោភសេពសន្ថវៈ ឈ្មោះប៊ុន ហុក អាយុ ២២ឆ្នាំ នាង ប៊ុន តី នាង ប៊ុន អឿន ពីបទផ្សំគំនិត ប្រព្រឹត្តនៅភូមិព្រៃកញ្ចៀ ឃុំព្រៃកញ្ចៀ ស្រុកពញាឮ កាលពីថ្ងៃទី ២៥-៥-៩៨ និង ប្រព្រឹត្តនៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ៣១-៥-៩៨ តាមមាត្រា ៣៥ ,៣៣ និង ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញ ដីកាសំរេចលើកលែងចោទប្រកាន់ របស់តុលាការខេត្តកណ្តាល :

១-/ ដីកាលើកលែងចោទប្រកាន់លេខ ៦២ ដលច.៩៨ ចុះថ្ងៃទី ៨-១២-៩៨ សំរេចលើកលែងចោទប្រកាន់ឈ្មោះ ប៉ាក ផល្លន់ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើត និង ទីលំនៅបច្ចុប្បន្នភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ ប៉ាក ផន ( រ ) ម្តាយឈ្មោះ ប៊ុន អឿន ( រ ) ទោសពីមុនគ្មាន ។ ជាប់ចោទពីបទ : បោកបញ្ឆោត បង្ខាំងមនុស្សខុសច្បាប់ និង រំលោភ

សេពសន្ទវៈ ប្រព្រឹត្តនៅភូមិត្រពាំងកក់ ភូមិព្រៃកញ្ចៀ ឃុំម្កាក់ ឃុំព្រៃកញ្ចៀ ស្រុកអង្គស្នួល ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី ២៥-៣១-៥-៩៨ និង សំរេចឱ្យដោះលែងឈ្មោះនេះ ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ បើជននោះមិនត្រូវឃុំខ្លួន ពីបទល្មើសអ្វីផ្សេងៗទៀតទេ ។

២-/ ដីកាលើកលែងចោទប្រកាន់លេខ ៦៣ ដលច. ៩៨ ចុះថ្ងៃទី ៨-១២-៩៨ សំរេចលើកលែងចោទប្រកាន់ឈ្មោះ ប៊ុន ហុក ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ សាសនា ព្រះពុទ្ធ កើត និង ទីលំនៅសព្វថ្ងៃ ភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល ប្រពន្ធឈ្មោះ ខឹម ប៉ាក កូន ០១ នាក់ ឪពុកឈ្មោះ ប៊ុន ប្ញ ( រ ) ម្ដាយឈ្មោះ ប៊ុន គី ( រ ) ជាប់ចោទពីបទ ផ្សំគំនិត ប្រព្រឹត្តនៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៥-៣១-៩៨ និង សំរេចឱ្យដោះលែងឈ្មោះនេះ ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ បើជននោះមិនត្រូវឃុំខ្លួន ពីបទល្មើសអ្វីផ្សេងទៀតទេ ។

៣-/ ដីកាលើកលែងចោទប្រកាន់លេខ ៦៤ ដលច.៩៨ ចុះថ្ងៃទី ០៨-១២-៩៨ សំរេចលើកលែងចោទប្រកាន់ឈ្មោះ ប៊ុន អឿន ភេទស្រី អាយុ ៥៨ឆ្នាំ ជាប់ចោទពីបទ ផ្សំគំនិត ប្រព្រឹត្តនៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៥-៣១ -៥-៩៨ និង សំរេចឱ្យដោះលែងឈ្មោះនេះចេញពីមន្ទីឃុំឃាំងជាបន្ទាន់ បើជននោះមិនត្រូវឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

៤-/ ដីកាលើកលែងចោទប្រកាន់លេខ ៦៥ ដលច.៩៨ ចុះថ្ងៃទី ៨-១២-៩៨ សំរេចលើកលែងចោទប្រកាន់ឈ្មោះ ប៊ុន គី ភេទស្រី អាយុ ៥៨ ឆ្នាំ ជាប់ចោទពីបទផ្សំគំនិត ប្រព្រឹត្តនៅភូមិត្រពាំងកក់ ឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី ២៥-៣១ -៥-៩៨ និងសំរេចឱ្យដោះលែងឈ្មោះនេះ ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ បើជននោះមិនត្រូវឃុំខ្លួន ពីបទល្មើសអ្វីផ្សេងទៀតទេ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់លោកព្រះរាជអាជ្ញា អម តុលាការខេត្តកណ្ដាល ដែលប្ដឹងតវ៉ាពីដីកាលើកលែងចោទប្រកាន់ទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា :

១-/ ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៤២ ចុះថ្ងៃទី ០៨-១២-៩៨ របស់លោកព្រះរាជអាជ្ញា អម តុលាការខេត្តកណ្ដាល ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-/ តម្កល់ដីកាលើកលែងចោទប្រកាន់លេខ ៦៤ ដលច.៦៥ ដលច. ចុះថ្ងៃទី ៨-១២-៩៨ របស់ចៅក្រមស៊ើបអង្កេត ទុកជាបានការតទៅ ។

៣-/ តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៦២ ដលច. ចុះថ្ងៃទី ៨-១២-៩៨ របស់ចៅក្រមស៊ើបអង្កេតទុកជាបានការតទៅ លើកលែងតែចំណុចដែលសំរេចលើកលែងចោទ ពីបទបង្ខាំងមនុស្សខុសច្បាប់ ដែលត្រូវបដិសេធចោល ។

៤-/ តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៦៣ ដលច. ចុះថ្ងៃទី ៨-១២-៩៨ របស់ចៅក្រមស៊ើបអង្កេត ទុកជាបានការតទៅ លើកលែងតែចំណុចដែលសំរេចលើកលែងចោទ ពីបទសមគំនិត ក្នុងបទបង្ខាំងមនុស្សខុសច្បាប់ ដែលត្រូវបដិសេធចោល និង តែតម្រូវការចោទប្រកាន់ឱ្យបានត្រឹមត្រូវឡើងវិញ ។

៥-/ ចោទប្រកាន់ឈ្មោះ ប៉ាក ផល្លន់ និង ឈ្មោះ ប៊ុន ហុក ពីបទបង្ខាំងមនុស្សខុសច្បាប់ ប្រព្រឹត្តនៅភូមិក្តីស្នួល ឃុំត្រពាំងជន ស្រុកបាកាន ខេត្តពោធិសាត់ កាលពីថ្ងៃទី ២៥-០៥-៩៨ ដល់ថ្ងៃទី ០១-០៦-៩៨ តាមបទបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦-/ បញ្ជូនសំណុំរឿង និងជនជាប់ចោទ ទៅតុលាការខេត្តកណ្តាល ដើម្បីជំនុំជំរះ តាមច្បាប់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៦៨ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១/- ទទួលបណ្តឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា ឆេង ផាត់ ចុះថ្ងៃទី ០៨-១២-៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២/- តម្កល់ដីកាលើកលែងចោទប្រកាន់លេខ ៦២ , ៦៣ , ៦៤ និង ៦៥ ដលច.៩៨ ចុះថ្ងៃទី ០៨-១២-១៩៩៨ របស់តុលាការខេត្តកណ្តាល ទុកជាបានការ ។

៣/- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៧២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ១៩៩៩ របស់ អគ្គព្រះ-រាជអាជ្ញា អម សាលាឧទ្ធរណ៍ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៦៨ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី 06 ខែ តុលា ឆ្នាំ 1999 របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាបណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ " ។

- បានឃើញសារណោតប ចុះថ្ងៃទី 17 ខែ ធ្នូ ឆ្នាំ1999 របស់ជនជាប់ចោទឈ្មោះ ប៉ាក់ ផល្លន់ ជាចុងបណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ " ។

- បានឃើញសារណោតប ចុះថ្ងៃទី 17-12-1999 របស់ជនជាប់ចោទឈ្មោះ ប៉ាក -ផល្លន់ , ចុះថ្ងៃទី 18-12-1999 របស់ឈ្មោះ ប៊ូ គី , ចុះថ្ងៃទី 16-12-1999 របស់ឈ្មោះ ប៊ុន ហុក , ចុះថ្ងៃទី 19-12-1999 របស់ឈ្មោះ ប៊ុន អឿន ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

សាលដីកាព្រហ្មទណ្ឌលេខ168 ចុះថ្ងៃទី 02 ខែកក្កដា ឆ្នាំ1999 របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ ត្រឹមត្រូវហើយ ។

ហេតុនេះ សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

- ក្រឡាបញ្ជីអានសេចក្តីសន្និដ្ឋានបណ្តឹងសាទុក្ខ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់ លោក ប៉ាក់ ផល្លន់ " ជាចុងបណ្តឹងសាទុក្ខ " នាពេលសវនាការថា : ខ្ញុំបាទពុំមានយោបល់អ្វី ដើម្បីឆ្លើយតូទ តុលាការទេ ខ្ញុំសូមយកចម្លើយរបស់ខ្ញុំបាទតាម

សារណា ។ ខ្ញុំបាទពុំបានបង្ខំនាង មុយ លីទាវ ទេ រឿងនេះមានការព្រមព្រៀងគ្នាទាំងសងខាង ព្រោះខ្ញុំបាទ និង មុយ លីចាន់ បានស្រលាញ់គ្នា ។

- បានស្ដាប់ចម្លើយអះអាងរបស់ លោក ប៊ុន ហុក " ជាចុងបណ្ដឹងសាទុក្ខ " នាពេលសវនាការថា : ខ្ញុំអត់បានដឹងពីតំរោងការរត់របស់ គេទាំងពីរនាក់ទេ មុយ លីចាន់ សុំអង្វរឱ្យខ្ញុំ ជួយឌុបម៉ូតូទៅបេនឡាន ។ មុយ លីចាន់ និង ខ្ញុំបាទស្គាល់គ្នាមិនជិតស្និទទេ ។

- បានស្ដាប់ចម្លើយអះអាងរបស់ អ្នកស្រី ប៊ុន គី " ជាចុងបណ្ដឹងសាទុក្ខ " នាពេលសវនាការថា : ខ្ញុំអត់ដឹងរឿងទេ កូនទៅរៀននៅភ្នំពេញ។ ខ្ញុំដឹងថា មានរឿងតាមអ្នកភូមិនិយាយប្រាប់ ក៏តាមរកកូន ក៏បានជួបកូន និង មុយ លីចាន់ ។ ខ្ញុំក៏សួរទៅកូនថា ហេតុអ្វីក៏នាំគ្នាមក នាង មុយ លីចាន់ ឆ្លើយថា " ខ្ញុំបានឱ្យគាត់ជូនខ្ញុំមក អ៊ុំ កុំភ័យ ខ្ញុំធានា " ខ្ញុំក៏ហៅទៅធ្វើកំណត់ហេតុនៅរដ្ឋអំណាច តែរដ្ឋអំណាចឥតមកធ្វើ ។

- បានស្ដាប់ចម្លើយអះអាងរបស់ អ្នកស្រី ប៊ុន អឿន " ជាចុងបណ្ដឹងសាទុក្ខ " នាពេលសវនាការថា : ខ្ញុំបាទឱ្យកូនប្រសារទៅប្ដឹងរដ្ឋអំណាច ព្រោះអ្នកទាំងបីនាក់បានមកដល់ ផ្ទះខ្ញុំទាំងយប់ព្រលប់ តែរដ្ឋអំណាចមិនមកធ្វើកំណត់ហេតុ ។ ខ្ញុំដឹងតាមពួកឃុំ ថាមានមាស ៧តំលឹង ។

- បានស្ដាប់ចម្លើយអះអាងរបស់ លោក ហួត សុខុន " ជាចុងបណ្ដឹងសាទុក្ខ " នាពេលសវនាការថា : ថ្ងៃទី ២៥-៥-៩៨ ពេលខ្ញុំទៅធ្វើការបាត់ពេលត្រលប់មកផ្ទះវិញ មានអ្នកភូមិនោះឡោថាមានមនុស្សប្រុសមកផ្ទះរបស់ខ្ញុំហើយ ឌុបប្រពន្ធ និង កូនខ្ញុំចេញទៅក្រៅ ។ ខ្ញុំបាទតាមរកប្រពន្ធក៏ទៅឃើញនៅជាមួយមនុស្សប្រុសពីរនាក់ ឈ្មោះ ប៉ាក ផល្លន់ និង ប៊ុន ហួត ។ តាមចម្លើយរបស់ ប៉ាក ផល្លន់ និង ប៊ុន ហួត មិនត្រឹមត្រូវទេ ព្រោះនៅសាលាឧទ្ធរណ៍ ប៉ាក ផល្លន់ បានឆ្លើយថា ខ្លួនបានយកប្រេងខ្យល់ទៅលាបឱ្យប្រពន្ធខ្ញុំនៅលើឡាន ឯនៅតុលាការកំពូល បែរជាឆ្លើយថា ខ្លួនគ្មានប្រេងខ្យល់ទេវិញ ។ ប្រពន្ធខ្ញុំទៅផ្ទះ ពាក់អាវយឺតមជ្ជូក និង ខោពណ៌ខ្មៅ ។

- បានស្ដាប់ចម្លើយអះអាងរបស់ អ្នកស្រី មុយ លីចាន់ នាពេលសវនាការថា : នៅព្រឹកថ្ងៃកើតហេតុ ឈ្មោះ ប៊ុន ហុក បានយកម៉ូតូមកឌុបនាងខ្ញុំទៅភ្នំពេញ។ ដើម្បីទៅទិញគ្រឿងធ្វើមាសឱ្យ ប៉ាក ផល្លន់ ។ នាងខ្ញុំចេញពីផ្ទះអត់បានយកសំពាយឥវ៉ាន់អ្វីទេ យកតែកូនទៅតាម ។ នាងខ្ញុំបានឡើងជិះឡាន គាក់ ស៊ី ដោយមិនដឹងខ្លួន ។ កំពុងនៅលើឡានតាក់ស៊ី ប៉ាក ផល្លន់ បានយកប្រេងខ្យល់មកលាកឱ្យខ្ញុំ។ ងងុយដេក ឥតដឹងខ្លួនរហូត ។ នាងខ្ញុំបាត់បង់ស្មារតី គ្រាន់តែដឹងថា បានស្នាក់នៅក្នុងផ្ទះតូច១ នៅក្នុងព្រៃឆ្ងាយ ។ ខ្ញុំយកមាស ៧ តំលឹង ៣ជី, ២៥០ ដុល្លា, លុយខ្មែរ១៨៥ ម៉ឺនរៀល និងគ្រឿងអលង្កាជាប់ខ្លួន តែគ្មានខោអាវទេ។ ផល្លនជាអ្នកចាប់ខ្ញុំបញ្ចូលឡាន ។ ប៊ុន ហុក ពរកូនខ្ញុំបញ្ចូលឡាន ក្នុងឡានមានខ្ញុំ, កូនខ្ញុំ, ផល្លន់, ប៊ុន ហុក និង តាកុង ។ ខ្ញុំយកមាសមកច្រើន ដើម្បីមកដូរគ្រឿងនៅភ្នំពេញ។។ គេទាំងពីរនាក់នាំខ្ញុំទៅរស់នៅខេត្តពោធិសាត់ បាន ១អាទិត្យ ។ នៅពេលចេញពីផ្ទះទៅ នាងខ្ញុំស្លៀកខោខ្មៅ និង អាវផ្កា ។

តំណាងមហាអយ្យការ បានមានយោបល់បន្ថែមនាពេលសវនាការថា : ចម្លើយរបស់ជនរងគ្រោះមិនសូវស្គាល់គ្នា តែហេតុម្តេចក៏នៅពេល ប៊ុន ហុក ទៅហៅហេតុអី ក៏នាង មុយ លីចាន់ ដាក់មាស ច្រើនតាមខ្លួនម្លេះ ហើយហេតុអីក៏យកទៅដូរនៅបេនឡាន ស្វាយរៀង ។ ម្យ៉ាងទៀតនៅពេលដល់បេនឡាន ហេតុអ្វីក៏នាងមិនស្រែកនៅបេនឡានស្វាយរៀង ឱ្យគេជួយ ព្រោះនៅបេនឡានមានមនុស្សច្រើនណាស់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយដោះសាររបស់ជនជាប់ចោទ និង ចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ 72 ចុះថ្ងៃទី 17-8-99 របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា 14 នៃច្បាប់ ស្តីពី ការរៀបចំតាំង និង សកម្មភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា ការដែលអគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍សន្និដ្ឋានថា សាលាឧទ្ធរណ៍មិនបានលើកឡើង អំពីសំអាងហេតុគ្រប់គ្រាន់ ក្នុងការមិនចោទប្រកាន់បទបង្ខាំងមនុស្សខុសច្បាប់ ហើយមិនបានវែកញែកសំអាងហេតុឱ្យបានត្រឹមត្រូវ និង មានភាពច្របូកច្របល់នោះ ជាការត្រឹមត្រូវហើយ ប៉ុន្តែកំហុសនេះ មិនអាចនាំឱ្យមោឃៈសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍បានទេ ពីព្រោះអង្គហេតុ នៃ រឿងនេះបង្ហាញឱ្យឃើញថា ឈ្មោះចាក់ ផលួន ឈ្មោះ ប៊ុន ហុក , ប៊ុន គី និង ប៊ុន អឿន ពិតជាពុំមានពិរុទ្ធមែន។
- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ 168 ចុះថ្ងៃទី 02-7-99 របស់សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និង គតិច្បាប់ហើយ ។

### ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះ .**

១- ទទួលបណ្តឹងសាទុក្ខលេខ 72 ចុះថ្ងៃទី 17-8-99 របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-　តម្កល់សាលដីកាព្រហ្មទណ្ឌលេខ 168 ចុះថ្ងៃទី 02-7-99 របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-　សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី 22 ខែ មីនា ឆ្នាំ 2000 និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី 24 ខែ មីនា ឆ្នាំ 2000 ។